ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ:៥២.៨.....សហវ..

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរង្វាន់ប្រាក់ជំនួសឱ្យបុរេប្រទានសម្រាប់ឆ្នាំ២០១៦ របស់បេឡាជាតិអតីតយុទ្ធជន

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**នាយក**
**បេឡាជាតិអតីតយុទ្ធជន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹតលេខ៨២ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹតលេខ ៨១អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វ័យយ័ត រាជធានីភ្នំពេញ និង អង្គភាពសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីកាអនុវត្តបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញប្រកាសលេខ២១១សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបេឡាជាតិអតីតយុទ្ធជន

**សម្រេច**

**ប្រការ១** : ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០"កាទិញ", ជំពូក៦១"សេវាកម្ម", ជំពូក៦៤"បន្ទុកបុគ្គលិក" នៅបេឡាជាតិអតីតយុទ្ធជនសម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ ថ្មីនៃប្រកាស៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២** : ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទានត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤** : នាយកខុទ្ទកាល័យ អគ្គនាយកនៃរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាន នាយកបេឡាជាតិអតីតយុទ្ធជន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបេឡាជាតិអតីតយុទ្ធជន ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**នាយក**
**បេឡាជាតិអតីតយុទ្ធជន**

**ហែម_ប៊ូរ៉ា**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មូលនិធិជាតិអតីតយុទ្ធជន

## តារាងឧបសម្ព័ន្ធវិទេយ្យបុរេប្រទានថវិកាកម្មវិធី ឆ្នាំ២០១៦

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានខ្ទាត់ធម្មតា | ឥណទានវិទេយ្យបុរេប្រទាន | ឥណទាន១ជុំបង្វិលវិទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3=1-2 | 4 | 5=4/4ជុំ | 6=4/2 |
| | | | **សរុបរួម** | **2,538,554,000** | **2,538,554,000** | **1,527,824,200** | **1,010,729,800** | **252,682,450** | **39.82%** |
| 60 | | | ការទិញ | **1,262,966,000** | **1,262,966,000** | **884,076,200** | **378,889,800** | **94,722,450** | **30.00%** |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | **263,100,000** | **263,100,000** | **184,170,000** | **78,930,000** | **19,732,500** | **30.00%** |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ | 63,000,000 | 63,000,000 | 44,100,000 | 18,900,000 | 4,725,000 | 30.00% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 200,100,000 | 200,100,000 | 140,070,000 | 60,030,000 | 15,007,500 | 30.00% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | **999,866,000** | **999,866,000** | **699,906,200** | **299,959,800** | **74,989,950** | **30.00%** |
| | | 60021 | សម្ភារៈការិយាល័យ និងការបោះពុម្ព | 999,866,000 | 999,866,000 | 699,906,200 | 299,959,800 | 74,989,950 | 30.00% |
| 61 | | | សេវាកម្ម | **1,067,288,000** | **1,067,288,000** | **534,548,000** | **532,740,000** | **133,185,000** | **49.92%** |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | **36,000,000** | **36,000,000** | - | **36,000,000** | **9,000,000** | 100% |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុង និងក្រៅប្រទេស | **62,840,000** | **62,840,000** | - | **62,840,000** | **15,710,000** | 100% |
| | 6105 | | ការថែទាំ និងជួសជុល | **188,240,000** | **188,240,000** | **131,768,000** | **56,472,000** | **14,118,000** | **30.00%** |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 48,000,000 | 48,000,000 | 33,600,000 | 14,400,000 | 3,600,000 | 30.00% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 140,240,000 | 140,240,000 | 98,168,000 | 42,072,000 | 10,518,000 | 30.00% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយ នៃការប្រើប្រាស់សៅ និង | **34,000,000** | **34,000,000** | - | **34,000,000** | **8,500,000** | **100%** |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 34,000,000 | 34,000,000 | - | 34,000,000 | 8,500,000 | 100% |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | **158,408,000** | **158,408,000** | - | **158,408,000** | **39,602,000** | **100%** |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 15,000,000 | 15,000,000 | - | 15,000,000 | 3,750,000 | 100% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 74,608,000 | 74,608,000 | - | 74,608,000 | 18,652,000 | 100% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 18,000,000 | 18,000,000 | - | 18,000,000 | 4,500,000 | 100% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍នៅក្នុង និងក្រៅប្រទេស | 2,000,000 | 2,000,000 | - | 2,000,000 | 500,000 | 100% |
| | | 61107 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 48,800,000 | 48,800,000 | - | 48,800,000 | 12,200,000 | 100% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាន និងឯកសារ | **2,400,000** | **2,400,000** | - | **2,400,000** | **600,000** | **100%** |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 2,400,000 | 2,400,000 | - | 2,400,000 | 600,000 | 100% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 6112 | | ចំណាយខ្ទាត់សោហ៊ុយក្នុងប្រទេស | 538,560,000 | 538,560,000 | 376,992,000 | 161,568,000 | 40,392,000 | 30% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 158,400,000 | 158,400,000 | 110,880,000 | 47,520,000 | 11,880,000 | 30% |
| | | 61122 | សោហ៊ុយបេសកកម្ម | 52,800,000 | 52,800,000 | 36,960,000 | 15,840,000 | 3,960,000 | 30% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 327,360,000 | 327,360,000 | 229,152,000 | 98,208,000 | 24,552,000 | 30% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | 46,840,000 | 46,840,000 | 25,788,000 | 21,052,000 | 5,263,000 | 44.94% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 10,000,000 | 10,000,000 | - | 10,000,000 | 2,500,000 | 100% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 36,840,000 | 36,840,000 | 25,788,000 | 11,052,000 | 2,763,000 | 30.00% |
| 64 | | | បន្ទុកបុគ្គលិក | 208,300,000 | 208,300,000 | 109,200,000 | 99,100,000 | 24,775,000 | 47.58% |
| | 6401 | | ប្រាក់កម្រៃសម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាល | 156,000,000 | 156,000,000 | 109,200,000 | 46,800,000 | 11,700,000 | 30% |
| | | 64016 | ប្រាក់កម្រៃសម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាល | 156,000,000 | 156,000,000 | 109,200,000 | 46,800,000 | 11,700,000 | 30% |
| | 6402 | | លាភការ និងប្រាក់បំណាច់បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍ | 24,300,000 | 24,300,000 | - | 24,300,000 | 6,075,000 | 100% |
| | | 64023 | ប្រាក់ម៉ោងបន្ថែម | 24,300,000 | 24,300,000 | - | 24,300,000 | 6,075,000 | 100% |
| | 6405 | | ប្រាក់កែជន៍សង្គមសម្រាប់មន្ត្រីរាជការ | 28,000,000 | 28,000,000 | - | 28,000,000 | 7,000,000 | 100% |
| | | 64058 | ប្រាក់កែជន៍សង្គមផ្សេងៗទៀតសម្រាប់មន្ត្រីរាជការ | 28,000,000 | 28,000,000 | - | 28,000,000 | 7,000,000 | 100% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២០....ខែមករា..ឆ្នាំ២០១៦
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឃើញ និងឯកភាព
ថ្ងៃទី២០....ខែមករា..ឆ្នាំ២០១៦
រដ្ឋមន្ត្រី

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១...
ជ. អគ្គនាយក
អគ្គនាយកដ្ឋានថវិកា

ខៀវ ប៉ូលីកាឌី

បានពិនិត្យត្រឹមត្រូវ
ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៥
ការិយាល័យហិរញ្ញវត្ថុ និងគណនេយ្យ

ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥
ជ្រោយរបស់ប្រធាន

គឹម_សាវឿន

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥
នាយកបេឡាជាតិអតីតយុទ្ធជន

ហោម_ប៊ុនរ៉ា